# សហព័ន្ធសហជីពកម្ពុជា

## CAMBODIAN ALLIANCE OF TRADE UNIONS


# សេចក្តីថ្លែងការណ៍

**សហព័ន្ធសហជីពកម្ពុជា** (កាទូ) ថ្កោលទោសនូវសកម្មភាពធ្វើទុក្ខបុកម្នេញ និងរើសអើងរបស់ក្រុមហ៊ុន **ត្រីប៉ូស អ៊ិនធើណេ សិនណល(ខេមបូឌា)ខូអិលធីឌី** ទៅលើថ្នាក់ដឹកនាំ សកម្មជន និងសមាជិករបស់សហជីពកម្ពុជាប្រចាំក្រុមហ៊ុនត្រីប៉ូស។ សហព័ន្ធ សហជីពកម្ពុជា សូមអំពាវនាវដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងភ្ញៀវរបស់ក្រុមហ៊ុន ដូចជាក្រុមហ៊ុន Clarks ឱ្យជួយធ្វើ អន្តរាគមន៍ដើម្បីធានាថាថ្នាក់ដឹកនាំ សកម្មជន និងសមាជិករបស់សហជីពកម្ពុជាប្រចាំក្រុមហ៊ុន **ត្រីប៉ូស** មានសិទ្ធិសេរីភាព ពេញលេញ ក្នុងការបង្កើត និងចូលជាសមាជិកសហជីពកម្ពុជា។

កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ សហព័ន្ធសហជីពកម្ពុជាបានជូនដំណឹងទៅក្រុមហ៊ុន **ត្រីប៉ូស** អំពី លទ្ធផលនៃការបោះឆ្នោតបង្កើតសហជីពកម្ពុជាប្រចាំក្រុមហ៊ុនត្រីប៉ូសលើកទីមួយ។ បើគិតត្រឹមដល់សព្វថ្ងៃនេះ សហព័ន្ធសហជីពកម្ពុជា បានរៀបចំការបោះឆ្នោតបង្កើតសហជីពមូលដ្ឋាននៅក្រុមហ៊ុនត្រីប៉ូស ចំនួន៣ដង ដោយសារតែក្រុមហ៊ុនតែងតែគំរាមកំហែងថ្នាក់ដឹកនាំ សកម្មជន និងសមាជិករបស់សហជីពកម្ពុជាឱ្យលាឈប់ពីសហជីពហើយផ្តិតមេដៃទៅលើលិខិតលាឈប់ពីសហជីព។ បន្ទាប់មកក្រុមហ៊ុនបានយក លិខិតទាំងនេះដាក់ ទៅមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង ព្រមទាំងលិខិតជំទាស់នឹងការចុះឈ្មោះសហជីពកម្ពុជា ចំនួន៣ដង។ សហព័ន្ធសហជីពកម្ពុជាបានកត់សម្គាល់ហេតុការណ៍ដែលក្រុមហ៊ុន**ត្រីប៉ូស**ធ្វើទុក្ខបុកម្នេញនិងរើសអើងនឹងសមាជិករបស់យើងចំនួន ៧ ករណីបន្ថែមទៀត។

បើយោងតាមទាំងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីសហជីព និងអនុសញ្ញាអន្តរជាតិ កម្មករ និយោជិតទាំងអស់ មានសិទ្ធិសេរីភាពក្នុងការបង្កើតសហជីព។ លើសពីនេះទៀត មាត្រា៦៣ នៃច្បាប់ស្តីពី សហជីព ចែងថា ការធ្វើការរើសអើងតាមវិធីណា មួយជាមួយ នឹងកម្មករនិយោជិតនៅក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ដើម្បីរៀបចំសហជីពដោយខ្លួនឯងត្រូវចាត់ទុកថាខុសច្បាប់។ កាលពីថ្ងៃ ទី០៣ ខែធ្នូ ឆ្នាំ២០២០ សហព័ន្ធសហជីពកម្ពុជា បានដាក់ពាក្យ បណ្តឹងទៅមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីអំពីសកម្មភាព ជ្រៀត ជ្រែកធ្វើទុក្ខបុកម្នេញ និងរើសអើង របស់ក្រុមហ៊ុន ត្រីប៉ូស ទៅលើថ្នាក់ដឹកនាំ សកម្មជន និងសមាជិករបស់សហជីពកម្ពុជា។ ប៉ុន្តែបើទោះបី ជាសហព័ន្ធសហជីពកម្ពុជាប្តឹងទៅមន្ទីរការងារក៏ដោយក៏ក្រុមហ៊ុនត្រីប៉ូស នៅតែបន្តធ្វើសកម្មភាពជ្រៀតជ្រែក ធ្វើទុក្ខបុកម្នេញ និងរើសអើង ទៅលើថ្នាក់ដឹកនាំ សកម្មជន និងសមាជិករបស់សហជីពកម្ពុជារហូតដល់សព្វថ្ងៃនេះ។ សហព័ន្ធសហជីពកម្ពុជា មិនអាចទទួល យកនូវទង្វើ បែបនេះទៅលើថ្នាក់ដឹកនាំ សកម្មជន និងសមាជិករបស់យើងបានទេ។

ហេតុដូច្នេះ ដើម្បីការពារផលប្រយោជន៍របស់ថ្នាក់ដឹកនាំ សកម្មជន និងសមាជិករបស់យើងនៅក្រុមហ៊ុន **ត្រីប៉ូស** សហព័ន្ធ សហជីពកម្ពុជា ថ្កោលទោសជាសាធារណៈនូវសកម្មភាពធ្វើទុក្ខបុកម្នេញ និងរើសអើងទាំងនេះហើយសូមអំពាវនាវ ដល់ក្រសួងការងារ និងភ្ញៀវរបស់ក្រុមហ៊ុនដូចជាក្រុមហ៊ុន Clarks ឱ្យជួយធ្វើអន្តរាគមន៍ដើម្បីធានាថាថ្នាក់ដឹកនាំ សកម្មជន និងសមាជិកសហជីពកម្ពុជា ប្រចាំក្រុមហ៊ុន **ត្រីប៉ូស** មានសិទ្ធិសេរីភាពពេញលេញក្នុងការបង្កើតនិងចូលជាសមាជិកសហជីពកម្ពុជា៕

ថ្ងៃចន្ទ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១

**ប្រធាន**

**យ៉ាង សុភ័ណ្ឌា**


អាសយដ្ឋាន៖ ផ្ទះលេខ១២B ផ្លូវលេខ៥ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ
Address: #12B Str.5 Phum Toulrokar Sangkat Chak Angre Krom, Khan Mean Chey, Phnom Penh, Cambodia
Tel: (855) 012 880 039, 089 887 701, 012 351 402 E-mail: thecatu@gmail.com / www.catucambodia.org

សហព័ន្ធសហជីពកម្ពុជា
CAMBODIAN ALLIANCE OF TRADE UNIONS

## Statement

**The Cambodian Alliance of Trade Unions** (CATU) condemns **Tripos International Cambodia Co., Ltd's** persecution and discrimination of leaders, members and activists of the Cambodian Union of Tripos. The Cambodian Alliance of Trade Unions calls on the Ministry of Labour and Vocational Training and brands sourcing from this factory, such as Clarks, to intervene and ensure that leaders, members and activists of the Cambodian Union of Tripos can fully exercise their rights and freedoms in forming and joining as members of the Cambodian Union.

On 19 November 2020, the Cambodian Alliance of Trade Unions notified Tripos International of the results of the first election to form the Cambodian Union of Tripos. As of today, the Cambodian Alliance of Trade Unions has organised three elections for formation of a trade union at Tripos, as management continually threaten the leaders, members and activists of the Cambodian Union to resign from the union and submit resignation letters to the union. Afterwards, the company has, on three occasions, taken these letters to the Kampong Chhnang Provincial Department of Labour and Vocational Training with a letter objecting to the registration of the Cambodian Union. We have detailed at least seven separate instances of persecution and discrimination against our members at Tripos.

According to the Cambodian Constitution, the Law on Trade Unions and international conventions, all workers have the right to form trade unions. As well as this, Article 63 of the Law on Trade Unions states that interference by any means with workers in the exercise of their rights to form a trade union is to be considered illegal. On 3 December 2020, the Cambodian Alliance of Trade Unions filed a complaint with the local Department of Labour about Tripos' interference with, persecution of and discrimination against the leaders, activists and members of the Cambodian Union. However, despite our complaint to the Department of Labour, Tripos continues to interfere with, persecute and discriminate leaders, activists and members of the Cambodian Union until today. The Cambodian Alliance of Trade Unions cannot accept these sorts of acts against our members.

Therefore, in order to protect our members' interests at Tripos, the Cambodian Alliance of Trade Unions publicly condemns these acts of persecution and discrimination and calls on the Ministry of Labour and brands sourcing from the factory such as Clarks to intervene and ensure that leaders, members and activists have full rights and freedom in forming and joining as members of the Cambodian Union.

Phnom Penh 5 April 2021

**President**

**Yang Sophorn**

Address: #12B Str.5 Phum Toulrokar Sangkat Chak Angre Krom, Khan Mean Chey, Phnom Penh, Cambodia
Tel: (855) 012 880 039, 089 887 701, 012 351 402 E-mail: thecatu@gmail.com / www.catucambodia.org